ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខៈ ០៣៤៧/១៣ អ.ជ.ប.គ.ញ

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែសីហា ឆ្នាំ២០១៣

# របាយការណ៍

## ស្តីពី

## លទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀន ខែ កក្កដា ឆ្នាំ២០១៣ និងទិសដៅការងារ ខែ សីហា ឆ្នាំ២០១៣

(ពីថ្ងៃទី ០១/៧/២០១៣ ដល់ ថ្ងៃទី ៣១/៧/២០១៣)

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តយកចិត្តទុកដាក់អនុវត្តន៍តាមយុទ្ធសាស្ត្រពហុវិស័យ នៃផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដើម្បីរួមចំណែកអនុវត្តន៍ "គោលនយោបាយ ភូមិ-ឃុំ មានសុវត្ថិភាព" របស់រាជរដ្ឋាភិបាល សំដៅរក្សាសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ ស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៤នៃរដ្ឋសភា ។ ជាក់ស្តែង លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលបានអនុវត្តនៅក្នុងខែកក្កដា ឆ្នាំ២០១៣ នេះ មានដូចខាងក្រោម :

## I. សភាពការណ៍គ្រឿងញៀននៅកម្ពុជា

តាមរបាយការណ៍របស់អង្គភាពអនុវត្តច្បាប់ រួមមាន មន្ទីរប្រឆាំងគ្រឿងញៀន និង រាជធានី-ខេត្តចំនួន ១៣ គឺ រាជធានីភ្នំពេញ, ខេត្តកណ្តាល, ខេត្តតាកែវ, ខេត្តកំពង់ចាម, ខេត្តព្រះសីហនុ, ខេត្តសៀមរាប, ខេត្តស្វាយរៀង, ខេត្តស្ទឹងត្រែង, ខេត្តបាត់ដំបង, ខេត្តបន្ទាយមានជ័យ, ខេត្តពោធិ៍សាត់, ខេត្តកំពង់ធំ និង ខេត្តក្រចេះ ដែលបានរាយការណ៍ពីលទ្ធផល នៃកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន បានបង្ហាញថា សកម្មភាពចរាចរជួញដូរ ចែកចាយ និងប្រើប្រាស់គ្រឿងញៀន នៅតែបន្តកើតមាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ក្នុងចំណោមបទល្មើសគ្រឿងញៀនដែលបង្ក្រាបក្នុងខែកក្កដានេះ បានកត់សំគាល់ឃើញ មានពីរករណីមេតំហ្វេតាមីន (ICE) ដែលបណ្តាញនៃក្រុមឧក្រិដ្ឋជនគ្រឿងញៀនអន្តរជាតិ ធ្វើសកម្មភាពដឹកជញ្ជូនពីក្រៅប្រទេស ចូលមកកម្ពុជាតាមច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ១ លើក និង តាមច្រកអាកាសយានដ្ឋានអន្តរជាតិខេត្តសៀមរាប ១ លើក ត្រូវបានសមត្ថកិច្ចចម្រុះនៅតាមគោលដៅខាងលើបង្ក្រាបទាន់ពេលវេលា ។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ មានទីតាំងនៅក្នុងបរិវេណក្រសួងមហាផ្ទៃ, Phone, Fax: (855) 23 721 648, Fax: (855) 23 727 529
E-mail: info@nacd.gov.kh, Website : www.nacd.gov.kh

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### *អំពីការដឹកនាំអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន*

- ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានអនុញ្ញាតឱ្យគណៈប្រតិភូ នៃស្ថានឯកអគ្គរដ្ឋទូតអូស្ត្រាលី ចូលជួបសំដែងការគួរសម និងពិភាក្សាការងារ ក្នុងនោះ ពាក់ព័ន្ធសំខាន់លើការងារកាត់បន្ថយគ្រោះថ្នាក់ និងការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ដោយផ្អែកលើសហគមន៍ ។
- បានអនុញ្ញាតឱ្យក្រុមការងារ រៀបចំកិច្ចប្រជុំដើម្បីពិភាក្សាពីការស្នើសុំការគាំទ្រពីភាគីវៀតណាម លើកការផ្តល់សម្ភារៈ ឱសថ និងការបណ្តុះបណ្តាល បុគ្គលិក គ្រូពេទ្យ សម្រាប់មជ្ឈមណ្ឌលជាតិ ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។
- បានអនុញ្ញាតឱ្យថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ជួបពិភាក្សាការងារជាមួយអង្គការ FHI360 ដើម្បីពិនិត្យលទ្ធភាពក្នុងការផ្តល់សម្ភារៈបន្ថែម និងការរៀបចំរចនាសម្ព័ន្ធមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀនរបស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ដើម្បីដំណើរការលើការងារប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀនកាន់តែមានប្រសិទ្ធភាព ។

ទន្ទឹមនេះ ផ្តើមចេញពីគោលការណ៍ដឹកនាំនិងណែនាំរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិ ក៏ដូចជាផែនការអនុវត្តទិសដៅការងារ ដែលបានដាក់ចេញកាលពីខែមិថុនា ឆ្នាំ២០១៣ កន្លងទៅ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានបន្តអនុវត្តវិធានការពហុវិស័យទទួលបានលទ្ធផលដូចខាងក្រោម :

### *ក. ការកាត់បន្ថយតម្រូវការគ្រឿងញៀន*

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយមានការចូលរួមយ៉ាងសកម្មពីក្រសួង ស្ថាប័ន ជាសមាជិក អ.ជ.ប.គ.ញ និងក្រសួង-ស្ថាប័ន មួយចំនួនទៀត ជាអាទិ៍ អគ្គិសនីកម្ពុជា បានបន្តយកចិត្តទុកដាក់អនុវត្តការអប់រំតាមប្រព័ន្ធផ្សព្វផ្សាយតាមកម្មវិធីប្រចាំ ថ្ងៃ សប្តាហ៍ និង ខែ, ការអប់រំតាមសហគមន៍, ការបណ្តុះបណ្តាលធនធានមនុស្ស ទទួលបានលទ្ធផលគួរកត់សំគាល់ **ដូចមានក្នុងតារាងឧបសម្ព័ន្ធ ទី១ ។ ដោយឡែក :**

**អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ :**

- ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានចូលរួមជាវាគ្មិន នៅក្នុងសិក្ខាសាលារបស់សាកលវិទ្យាល័យអាស៊ី អឺរ៉ុប ដើម្បីផ្សព្វផ្សាយអប់រំពី គ្រោះថ្នាក់នៃគ្រឿងញៀន និងជំងឺអេដស៍ ដល់សាស្ត្រាចារ្យ និងនិស្សិតចំនួន **<u>៤០០</u>** នាក់ (១២/៧/២០១៣) និងនៅសាកលវិទ្យាល័យកម្ពុជាអន្តរជាតិ ចំនួន **<u>១៥០</u>** នាក់ (២៤/៧/២០១៣) ។
- បានចាត់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន ចូលរួមជាវាគ្មិនក្នុងពិធីបើកវគ្គបំផុសស្មារតីស្តីពី គម្រោងសហគមន៍ស្វែងរកការគាំទ្រសម្រាប់កាត់បន្ថយគ្រោះថ្នាក់ពីមេរោគអេដស៍/ជំងឺអេដស៍ ការប្រើបំពានគ្រឿងញៀន និងការជួញដូរមនុស្ស និងការពារអនីតិជន (សណ្ឋាគារសាន់វេ ១២/៧/២០១៣) ។ អ្នកចូលរួមមានចំនួន **<u>១០៧</u>** នាក់ ។
- បានចូលរួម តាមការអញ្ជើញរបស់ក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងសិក្ខាសាលាស្តីពី ការបង្ហាញលទ្ធផលអង្កេតដំបូងលើការអនុវត្តកម្មវិធី ការអប់រំបំណិនជីវិត ស្តីពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ សម្រាប់យុវជន ក្នុង និង

ក្រៅសាលារៀន ដែលមានស្ថាប័នពាក់ព័ន្ធចូលរួម ៤០ នាក់ (២៨/៦/២០១៣) ដើម្បីក្តាប់បានបញ្ហាពាក់ព័ន្ធនឹងគ្រឿងញៀន ។

**ជារួម** សកម្មភាពផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងជាសាធារណៈពីបញ្ហាគ្រឿងញៀន នៅតាមសហគមន៍ និងការងារបណ្តុះបណ្តាលធនធានជនបង្គោល ដែលបានអនុវត្តដោយក្រសួង-ស្ថាប័ន ជាសមាជិក អ.ជ.ប.គ.ញ និងក្រសួង-ស្ថាប័នដទៃទៀត ព្រមទាំងអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ រួមទាំងការប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន របស់គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត ចំនួន ៦ គឺ រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តស្ទឹងត្រែង ខេត្តតាកែវ និងខេត្តស្វាយរៀង នៅក្នុងខែកក្កដា ឆ្នាំ២០១៣ នេះ មានមហាជនចូលរួមសរុប ***២៣.៥៩៣ នាក់*** លើ ១១៩.១៨១ នាក់ នៃខែមិថុនា **ដូចមាននៅក្នុងតារាងឧបសម្ព័ន្ធទី១** ។

## *ខ. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន*

ខែកក្កដាឆ្នាំ២០១៣នេះ មន្ត្រីអនុវត្តច្បាប់គ្រប់សមាសភាព និងគ្រប់លំដាប់ថ្នាក់ បានបន្តអនុវត្តន៍យុទ្ធសាស្ត្រកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀនទទួលបានលទ្ធផលដូចខាងក្រោម :

### *ខ.១. ការងារបង្ក្រាបបទល្មើសគ្រឿងញៀន*

- **បទល្មើសគ្រឿងញៀន** បង្ក្រាបបាន **៥២** ករណី លើ ៤៩ ករណី នៃខែ មិថុនា ឆ្នាំ ២០១៣
- **ជនសង្ស័យ** ពាក់ព័ន្ធបទល្មើសគ្រឿងញៀន ឃាត់ខ្លួន **១១៧** នាក់ លើ ៩៤ នាក់ នៃខែ មិថុនា ឆ្នាំ២០១៣
- **ចាប់តាមដីកា មាន** ៤ ដីកា = ៣ នាក់ (ប្រុស) ជនជាតិខ្មែរ

ក្នុងចំនួនជនសង្ស័យពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀនដែលបានឃាត់ខ្លួន **១១៧** នាក់ ខាងលើ មានប្រុស ៩៦ នាក់ ស្រី ២១ នាក់ ក្នុងនោះ ជនជាតិ **ខ្មែរ** ១០៥ នាក់ (ស្រី ១២ នាក់), **វៀតណាម** ៩ នាក់ (ស្រី ៧ នាក់), ចិន ២ នាក់ (ស្រី ១ នាក់) ឥណ្ឌា ១ នាក់ (ស្រី) ត្រូវបានសមត្ថកិច្ចកសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងរាជធានី-ខេត្ត ។

~ **វត្ថុតាងគ្រឿងញៀនចាប់យក** រួមមាន

- មេតំហ្វេតាមីន (WY) ៤៧,៤៩ ក្រាម
- មេតំហ្វេតាមីនក្រាមម្សៅ (Ice) ៤.៣៣៣,៧៤ ក្រាម
- អ៊ិចស្តាស៊ី ៦,៣៥ ក្រាម
- កេតាមីន ៩៩២,១៣ ក្រាម
- ម្សៅពណ៌សសង្ស័យគ្រឿងញៀន ៣៩,៤២ ក្រាម និងសារធាតុផ្សេងៗទៀត **ដូចមានក្នុងតារាង ឧបសម្ព័ន្ធទី២**

~ **ទ្រព្យសម្បត្តិសំខាន់ៗពាក់ព័ន្ធនឹងបទល្មើសគ្រឿងញៀន ចាប់យក** រួមមាន :

ម៉ូតូ ២៤ គ្រឿង, រថយន្ត ២ គ្រឿង, ប្រាក់កម្ពុជា ១.០០៧.៩០០ រៀល, ប្រាក់ថៃ ២០ បាត, ប្រាក់វៀតណាម ១០.០០០ ដុង, ប្រាក់អាមេរិក ១៩៧ ដុល្លារ

### *ខ.២. ការត្រួតពិនិត្យ និងការគ្រប់គ្រងសារធាតុគីមីមុំ*

អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានសហការជាមួយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រុមប្រឹក្សាអភិវឌ្ឍន៍

កម្ពុជា ដើម្បីប្រមូលទិន្នន័យសារធាតុគីមីផ្សំ ដែលមានច្បាប់អនុញ្ញាតឱ្យនាំចូលនៅក្នុងខែកក្កដា ឆ្នាំ២០១៣ មានដូចខាងក្រោម :

~ សារធាតុគីមីគិតជា គីឡូក្រាម ចំនួន ៤៦៣.៧០០ Kgs **ដូចមានក្នុងតារាងឧបសម្ព័ន្ធទី២**

***ខ.៣. ការងារកោសលវិច័យលើសំណាកសង្ស័យថាគ្រឿងញៀន***

មន្ទីរពិសោធន៍គ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ បានធ្វើកោសលវិច័យលើសំណាកសង្ស័យជាគ្រឿងញៀន ដែលបញ្ជូនមកពីស្ថាប័នអនុវត្តច្បាប់នានា នៅក្នុងខែកក្កដានេះ សរុបបានចំនួន ៧៦ ករណី = ៨៨ សំណាក (**សំណាកអវិជ្ជមានសារធាតុញៀន** ៣ សំណាក = ២ % និង សំណាក**វិជ្ជមានសារធាតុញៀន** ៨៥ សំណាក = ៩៨ %) ក្នុងនោះគឺ ៖

-មេតំហ្វេតាមីនក្រាមម្សៅ ៦៤ សំណាក = ៧៧ % -មេតំហ្វេតាមីនគ្រាប់ ២១ សំណាក = ២១ %

## ***គ. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម***

### ***គ.១. កម្មវិធីកាត់បន្ថយគ្រោះថ្នាក់***

- បានចូលរួមកិច្ចប្រជុំប្រចាំឆ្នាំ២០១៣ រវាងអង្គការ ខាន់ណា និងអង្គការដៃគូ ដើម្បីពិនិត្យលទ្ធផលនៃការអនុវត្តពាក់កណ្តាលឆ្នាំ នៃផែនការយុទ្ធសាស្ត្ររបស់អង្គការ ខានណា ។ នៅក្នុងផែនការនោះ មានពាក់ព័ន្ធនឹងក្រុមប្រឈមមុខខ្ពស់ ដែលមិនគ្រាប់តែមានផ្ទុកមេរោគអេដស៍ប៉ុណ្ណោះទេ គឺថែមទាំងសេពគ្រឿងញៀនទៀតផង ។ ចំណុចនេះត្រូវបំពេញសកម្មភាពបន្ថែមសម្រាប់ ឆមាសទី២ ។ អ្នកចូលរួមចំនួន <u>**១៦០**</u> នាក់ មកពីអង្គការដៃគូ, ស្ថាប័នពាក់ព័ន្ធ, ទីភ្នាក់ងារអភិវឌ្ឍន៍ អ.ស.អ, ម្ចាស់ជំនួយ, អង្គការសហគមន៍ ។
- បានចូលរួមកិច្ចប្រជុំ លើកទី១ តាមការអញ្ជើញរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីពិគ្រោះយោបល់លើសេចក្តីព្រាងប្រកាសស្តីពី លក្ខខណ្ឌការងារ និងវិធានអនាម័យសុវត្ថិសុខការងារ នៃសហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន ផ្នែកសេវាកម្មបាន្ត (០៨/៧/២០១៣) ។

### • ***គ.២. ការព្យាបាល ស្តារនីតិសម្បទា បណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាហរណកម្ម***

**ការងារក្នុងប្រទេស**

- បានសម្របសម្រួលជាមួយក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រៀបចំកិច្ចប្រជុំ កាលពីថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣ នៅអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.៣ ដើម្បីពិភាក្សាលើការស្នើសុំភាគីវៀតណាមគាំទ្រផ្នែកសម្ភារៈ ឱសថ និងការបណ្តុះបណ្តាល បុគ្គលិក គ្រូពេទ្យ សម្រាប់បម្រើការនៅក្នុងមជ្ឈមណ្ឌលជាតិ ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។
- បានសហការ និងសម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ ពិសេស ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីចាត់វិធានការដោះស្រាយសំណូមពររបស់ប្រជាពលរដ្ឋនៅស្រុកបវេល ខេត្តបាត់ដំបង ពាក់ព័ន្ធនឹងប្រសិទ្ធភាពនៃការអប់រំ កែប្រែអ្នកញៀនគ្រឿងញៀននៅក្នុងមណ្ឌលបណ្តោះអាសន្ន ពិភពនៃក្តីសង្ឃឹម ។

**ការងារក្រៅប្រទេស**

- បានចាត់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងនាយកដ្ឋានជំនាញ និងសម្របសម្រួលជូនតំណាងក្រសួងសុខាភិបាល

(សរុប **៣** រូប) ទៅប្រទេសថៃ ដើម្បីចូលរួមសន្និសីទអាស៊ានឆ្នាំ២០១៣ ស្តីពី "ផែនទីបង្ហាញផ្លូវឆ្ពោះទៅកាន់ការព្យាបាលអ្នកញៀនគ្រឿងញៀនប្រកបដោយប្រសិទ្ធភាព" ដែលសន្និសីទនេះ មានការពាក់ព័ន្ធនឹងការពិនិត្យស្ថានភាពអ្នកប្រើគ្រឿងញៀននាពេលបច្ចុប្បន្ន និងយន្តការជំរុញការគ្រប់គ្រងអ្នកប្រើគ្រឿងញៀន (១៧-១៩/៧/២០១៣) ។

## ឃ. *ការពង្រឹងសមត្ថភាពអនុវត្តន៍ច្បាប់*

**ការងារក្នុងប្រទេស**

- អគ្គលេខាធិការស្តីទី បានទទួលជួបពិភាក្សាការងារជាមួយអង្គការ FHI360 ដើម្បីពិនិត្យលទ្ធភាពក្នុងការផ្តល់សម្ភារៈបន្ថែម, ពិនិត្យលទ្ធភាពក្នុងការផ្តល់អ្នកជំនាញការជូនមជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ (នៅអគ្គលេខាធិការដ្ឋានថ្ងៃទី១៨/៧/២០១៣) ។

**ការងារក្រៅប្រទេស**

- បានចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញរបស់អគ្គលេខាធិការ អ.ជ.ប.គ.ញ និងសម្របសម្រួលជូនមន្ត្រីអនុវត្តច្បាប់របស់ក្រសួងស្ថាប័នពាក់ព័ន្ធសរុបចំនួន **១៥** រូប ទៅទទួលការបណ្តុះបណ្តាលស្តីពី "ការគ្រប់គ្រង និងត្រួតពិនិត្យសារធាតុគីមីផ្សំគ្រឿងញៀនទៅសាលាបណ្ឌិតសភានគរបាលខេត្តយូណាន (២៣/៦-០៧/៧/២០១៣) ។

## ខ. *កិច្ចសហប្រតិបត្តិការអន្តរជាតិ*

ខែកក្កដាឆ្នាំ២០១៣នេះ អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ បានបន្តកិច្ចសហប្រតិបត្តិការអន្តរជាតិ មានដូចខាងក្រោម :

- បានចាត់ថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ ទៅចូលរួមសិក្ខាសាលាបង្កើតផែនការសកម្មភាពអនុតំបន់ថ្មី (SAP) ស្តីពីកិច្ចសហប្រតិបត្តិការត្រួតពិនិត្យគ្រឿងញៀន ដើម្បីផ្តល់ការអនុម័តទៅលើរាល់សកម្មភាព លទ្ធផល និង ទិន្នន័យដែលនឹងត្រូវដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពថ្មីនេះ (ក្រាប៊ី ប្រទេសថៃ ថ្ងៃ០៩-១១/៧/២០១៣) ។
- បានបំពេញបញ្ជីសំណួរសម្រាប់ការវាយតម្លៃថ្នាក់ជាតិរបស់កម្ពុជា នៃការអនុវត្តផែនការលម្អិត ASCC និង ចូលរួមកិច្ចប្រជុំបូកសរុបលទ្ធផលពាក់កណ្តាលអាណត្តិនៃការអនុវត្តផែនការ ASCC នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (១៥/៧/២០១៣) ។

***ការងារផ្សេងៗ :***

- បាននិងកំពុងបន្តការរៀបចំក្រុមបាល់ទាត់ សម្រាប់បម្រើឱ្យការងារផ្សព្វផ្សាយច្បាប់ និងការងារផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងអំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។
- បានបន្តពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃមូលនិធិរបស់អាជ្ញាធរជាតិ សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

# III. ផែនការសកម្មភាពការងារត្រួតពិនិត្យគ្រឿងញៀន ខែសីហា ឆ្នាំ២០១៣

ដើម្បីធានានិរន្តរភាពការងារពហុវិស័យក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ នឹងបន្តអនុវត្តន៍ទិសដៅសកម្មភាពការងារមួយចំនួនដូចខាងក្រោម :

## ១. ការកាត់បន្ថយតម្រូវការគ្រឿងញៀន

១.១. ចូលរួមជាវាគ្មិនក្នុងសិក្ខាសាលាអប់រំស្តីពី សភាពការណ៍គ្រឿងញៀន ផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សម្រាប់និស្សិតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ចំនួន ៣០០ នាក់ នាចុងខែកក្កដា ឆ្នាំ២០១៣ ។

១.២. ស្នើសុំទៅគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តសៀមរាប ដើម្បីផ្តល់កិច្ចសម្ភាសន៍តាមកម្មវិធី សភាអ៊ីនធឺណែត នៃស្ថានីយទូរទស្សន៍ ស៊ី.ធី.អិន និង ស៊ី.អិន.ស៊ី អំពីសកម្មភាព និងលទ្ធផលការងារត្រួតពិនិត្យគ្រឿងញៀនក្នុងភូមិសាស្ត្រខេត្តសៀមរាប ( ថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៣) ។

១.៣. បន្តកិច្ចសហការជាមួយក្រសួង-ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី-ខេត្ត បណ្តាក្រុមហ៊ុនឯកជន ដើម្បីរៀបចំបញ្ច្រាបខ្លឹមសារអប់រំពីបញ្ហាគ្រឿងញៀនទៅក្នុងការប្រគំតន្ត្រីផ្សព្វផ្សាយផលិតផលនានា នៅ តាមរាជធានី-ខេត្ត និងនៅតាមវិទ្យាល័យក្នុងរាជធានីភ្នំពេញ ។

១.៤. បន្តរៀបចំកម្មវិធីប្រដាល់ដណ្តើមខ្សែក្រវ៉ាត់ពានរង្វាន់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅស្ថានីយទូរទស្សន៍បាយ័ន និងស្ថានីយទូរទស្សន៍ ល្បីៗមួយចំនួនទៀត ដើម្បីបញ្ច្រាបការផ្សព្វផ្សាយអប់រំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន ។

១.៥. បន្តកិច្ចសហការជាមួយអគ្គនាយកដ្ឋានវិទ្យុ-ទូរទស្សន៍ សមាគមទូរទស្សន៍ សមាគមមិត្តសិល្បករ តន្ត្រីករ ដើម្បីជំរុញកម្មវិធីផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹងពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយរបស់រដ្ឋ និងឯកជន ។

## ២. ការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន

២.១. សហការសម្របសម្រួលជាមួយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ដើម្បី :

- រៀបចំសៀវភៅបញ្ជីគ្រប់គ្រងសារធាតុគីមី ដែលមានចែងនៅក្នុងតារាងទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។
- រៀបចំស្លាកសញ្ញាសារធាតុគីមីជាភាសាខ្មែរ សម្រាប់បិទលើសំបកវេចខ្ចប់ ។
- ជំរុញបន្ថែមឱ្យម្ចាស់រោងចក្រ សិប្បកម្ម ប្រើប្រាស់ពាក្យស្លោក "គ្រឿងញៀនបំផ្លាញជីវិតអ្នក" បិទនៅលើផលិតផលរបស់ខ្លួន ។
- រៀបចំ Help Desk ដើម្បីផ្តល់ប្រឹក្សាដល់វិស័យឯកជន និងគ្រប់ភាគីពាក់ព័ន្ធ ។
- រៀបចំវគ្គបណ្តុះបណ្តាលដល់វិស័យឯកជន រួមទាំងកម្មករ អំពីការទុកដាក់ ការប្រើប្រាស់សារធាតុគីមី និងសារធាតុគ្រោះថ្នាក់ នៅតាមរោងចក្រ សិប្បកម្ម និង ក្រុមហ៊ុន ។

## ៣. ការកាត់បន្ថយគ្រោះថ្នាក់ ការព្យាបាល ស្តារនីតិសម្បទា ផ្តល់វិជ្ជាជីវៈ និងសមាហរណកម្ម

៣.១. គ្រៀមបញ្ជូនក្រុមការងារទៅប្រទេសវៀតណាមដើម្បីពិភាក្សាការងារពាក់ព័ន្ធនឹងការព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។

៣.២. សហការជាមួយក្រសួងសុខាភិបាល ដើម្បីរៀបចំឯកសារដែលពាក់ព័ន្ធនឹងការបង្ការ ការថែទាំ និងព្យាបាលបន្ត និងស្តារនីតិសម្បទាចិត្ត-សង្គម ចំពោះអ្នកប្រើប្រាស់គ្រឿងញៀន និងអ្នកចាក់គ្រឿងញៀន ។

៣.៣. រៀបចំយន្តការ និងបែបបទសម្រាប់ការអនុវត្តកម្មវិធី ម្ជុល/សឺរ៉ាំង តាមប្រព័ន្ធសុខាភិបាល ។

៣.៤. បន្តការផ្តល់សេវាថែទាំ ព្យាបាល និងផ្តល់របបឧបត្ថម្ភដល់អ្នកញៀនគ្រឿងញៀនដែលកំពុងសម្រាកព្យាបាល នៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ។

៣.៥. បន្តកិច្ចសហការសម្របសម្រួលជាមួយក្រសួងសុខាភិបាល ជំរុញការអនុវត្តកម្មវិធី មេតាដូន នៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ។

៣.៦. បន្តរៀបចំឯកសារគោលសម្រាប់មន្ត្រីអនុវត្តន៍ច្បាប់ ក្នុងការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។

## ៤. ការពង្រឹងសមត្ថភាពការងារអនុវត្តន៍ច្បាប់

៤.១. សហការជាមួយអង្គការ UNODC រៀបចំវគ្គបណ្តុះបណ្តាលស្តីពីការប្រយុទ្ធប្រឆាំងការចរាចរខុសច្បាប់ សម្រាប់មន្ត្រីបម្រើការជូរមុខ ( ថ្ងៃ២០-២៣/៨/២០១៣) ។

៤.២. ត្រៀមកិច្ចសហការសម្របសម្រួលជាមួយក្រសួងការពារជាតិ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាលដល់កងយោធពលខេមរភូមិន្ទ ដែលឈរជើងនៅតាមខ្សែបន្ទាត់ព្រំដែន ជាពិសេសខ្សែបន្ទាត់ព្រំដែននៃបណ្តាខេត្តនៅភាគឦសាន ។

៤.៣. បន្តរៀបចំវគ្គបណ្តុះបណ្តាល ការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តន៍ច្បាប់តាមប្រព័ន្ធកុំព្យូទ័រ ( កម្មវិធី CBT) ។

៤.៤. បន្តកិច្ចសហការជាមួយអង្គការFHI360 រៀបចំរចនាសម្ព័ន្ធរបស់មជ្ឈមណ្ឌលព័ត៌មានគ្រឿងញៀន ឱ្យបានច្បាស់លាស់ ដើម្បីបំពាក់ឧបករណ៍ សម្ភារៈ សម្រាប់ការងារប្រមូលទិន្នន័យព័ត៌មានគ្រឿងញៀន ។

៤.៥. រៀចបចំឯកសារសម្រាប់មន្ត្រីអនុវត្តច្បាប់ ក្នុងការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។

៤.៦. បន្តបញ្ជ្រាបកម្មវិធីសិក្សា ស្តីពីការកាត់បន្ថយគ្រោះថ្នាក់ ទៅក្នុងកម្មវិធីសិក្សារបស់សាលាបណ្ឌិត្យសភានគរបាលកម្ពុជា ។

៤.៧. ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោលស្តីពី កម្មវិធីកាត់បន្ថយគ្រោះថ្នាក់ ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ

៥.១. រៀបចំឯកសារពាក់ព័ន្ធនឹងការងារព្យាបាល ស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន សម្រាប់កិច្ចប្រជុំគណៈកម្មការចម្រុះ លើកទី១៣ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច វប្បធម៌ វិទ្យាសាស្ត្រ និងបច្ចេកទេស កម្ពុជា-វៀតណាម ដែលរៀបចំដោយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិកម្ពុជា នៅខេត្តព្រះសីហនុ ។

៥.២. ចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋាន ទៅទទួលការបណ្តុះបណ្តាលពង្រឹងប្រសិទ្ធភាពការងារពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់ នៅកម្ពុជា ( នៅទីក្រុងមែលប៊ន ប្រទេសអូស្ត្រាលី ១៩/៨-០៦/៩/២០១៣) ។

៥.៣. ចាត់បញ្ជូនថ្នាក់ដឹកនាំនាយកដ្ឋានជំនាញ របស់អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ទៅចូលរួមសិក្ខាសាលាកម្មវិធី Smart សាកល របស់អង្គការ UNODC ថ្នាក់តំបន់អាស៊ីអាគ្នេយ៍ និងអាស៊ីបូព៌ា ( នៅទីក្រុងហ្សាការតា ប្រទេសឥណ្ឌូនេស៊ី ២៨-២៩/៨/២០១៣) ។

៥.៤. រៀបចំដំណើរទស្សនកិច្ច សម្រាប់គណៈប្រតិភូនៃអគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ ទៅទស្សនកិច្ចនៅខេត្តយូណាន ប្រទេសចិន ។

៥.៥. រៀបចំពិធីទទួលសម្ភារៈ ដែលឧបត្ថម្ភដោយគណៈកម្មការធិការជាតិត្រួតពិនិត្យគ្រឿងញៀនចិន (NNCC) តាមរយៈអង្គការ UNODC ។

៥.៦. រៀបចំបញ្ជូនមន្ត្រីអនុវត្តច្បាប់ចំនួន ៣០ រូប ទៅទទួលវគ្គបណ្តុះបណ្តាលស្តីពីការអនុវត្តច្បាប់ត្រួតពិនិត្យគ្រឿងញៀន នៅបណ្ឌិត្យសភានគរបាល ខេត្តយូណាន សាធារណរដ្ឋប្រជាមានិតចិន ។

ក្រៅពីទិសដៅការងារខាងលើ អគ្គលេខាធិការដ្ឋាននឹងបន្តអនុវត្តការងារមួយចំនួនទៀត ដើម្បីបំពេញឱ្យយុទ្ធសាស្ត្រជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន មានដូចជា :

- រៀបចំផ្សព្វផ្សាយជាផ្លូវការនូវ ទិន្នន័យអ្នកប្រើប្រាស់គ្រឿងញៀននៅកម្ពុជា ។
- បន្តការរៀបចំក្រុមបាវកថា ។
- បន្តការពិនិត្យលើសេចក្តីព្រាងអនុក្រឹត្យ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃមូលនិធិរបស់អាជ្ញាធរជាតិសម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។៚

អគ្គលេខាធិការ

ឧត្តមសេនីយ៍ឯក. លី_គឹមឡុង

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
-ឯកឧត្តម កៅ ខុនជាវ៉ា អនុប្រធាន អ.ជ.ប.គ.ញ
-ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី កែ គឹមយ៉ាន
"ដើម្បីជូនជ្រាប"
-ក្រសួង សមាជិក អ.ជ.ប.គ.ញ
-ក្រសួងផែនការ
-អគ្គលេខាធិការដ្ឋាន អ.ជ.ប.គ.ញ
-គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន រាជធានី-ខេត្ត
-នាយកដ្ឋាន សរុប នៃទីស្តីការគណៈរដ្ឋមន្ត្រី
"ដើម្បីមុខការ"
-ឯកសារ